# ការមានសិទ្ធិទទួលថ្នាំបង្ការ COVID-19

## ដូសដំបូង ដូសបន្ថែម និងដូសជំរុញសម្រាប់ថ្នាំបង្ការ[1] ជំងឺ COVID-19 ដែលបានអនុម័ត/អនុញ្ញាតឱ្យប្រើប្រាស់ដោយ FDA

| | ថ្នាំបង្ការប្រភេទ Pfizer[2]/Comirnaty | ថ្នាំបង្ការប្រភេទ Moderna[3] | ថ្នាំបង្ការប្រភេទ Johnson & Johnson (J&J) |
|---|---|---|---|
| **អាយុមានសិទ្ធិចាក់ថ្នាំបង្ការ** | មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅ[1] | មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ | មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ |
| **លំដាប់ដំបូង** | ចំនួន 2 ដូស ដោយមានគម្លាត 21 ថ្ងៃពីគ្នា | ចំនួន 2 ដូស ដោយមានគម្លាត 28 ថ្ងៃពីគ្នា | ចំនួន 1 ដូស |
| **ដូសបន្ថែម (ទី 3)**[3,4] | *បុគ្គលណា៖* **បានណែនាំយ៉ាងម៉ឺងម៉ាត់** ប្រសិនបើអ្នកមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ហើយដែលមាន ប្រព័ន្ធភាពស៊ាំខ្សោយ កម្រិតមធ្យម ឬធ្ងន់ធ្ងរ។ | | មិនបានណែនាំឱ្យចាក់ទេ។ សូមមើលចំណុចដូសជំរុញខាងក្រោម។ |
| | *ពេលណា៖* យ៉ាងហោចណាស់រយៈពេល 28 ថ្ងៃបន្ទាប់ពីការចាក់ដូសទីពីររបស់អ្នក | | |
| **ដូសជំរុញ**[3,5]<br><br>*ដូសជំរុញអាចជាថ្នាំបង្ការជំងឺ COVID-19 ប្រភេទណាក៏បាន (J&J Pfizer ឬ Moderna)* | *បុគ្គលណា៖* **បានណែនាំយ៉ាងម៉ឺងម៉ាត់** សម្រាប់មនុស្សគ្រប់គ្នាដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ។<br><br>សំខាន់ខ្លាំងណាស់ ប្រសិនបើអ្នក៖<br>• មានអាយុចាប់ពី 65 ឆ្នាំឡើងទៅ<br>• មានអាយុចាប់ពី 18 ឆ្នាំឡើងទៅ និងមាន បញ្ហាសុខភាពប្រចាំកាយ (មិនបញ្ចេញមុខ) ឬប្រឈមនឹងហានិភ័យនៃការប៉ះពាល់នឹងមេរោគនៅកន្លែងការងារ ឬនៅក្នុងសហគមន៍។ | | *បុគ្គលណា៖* **បានណែនាំយ៉ាងម៉ឺងម៉ាត់**សម្រាប់មនុស្សគ្រប់រូបដែលបានចាក់ថ្នាំបង្ការប្រភេទ J&J សម្រាប់លំដាប់ដំបូងរបស់ពួកគេ។<br><br>នេះរួមបញ្ចូលផងដែរ ប្រសិនបើអ្នកមាន ប្រព័ន្ធភាពស៊ាំខ្សោយ កម្រិតមធ្យម ឬធ្ងន់ធ្ងរ។ |
| | *ពេលណា៖* យ៉ាងហោចណាស់រយៈពេល 6 ខែបន្ទាប់ពីការចាក់ដូសទី 2 របស់អ្នក។[6] | | *ពេលណា៖* យ៉ាងហោចណាស់ 2 ខែបន្ទាប់ពីការចាក់ថ្នាំបង្ការប្រភេទ J&J របស់អ្នក។ |

1 **ប្រសិនបើអ្នកបានទទួលចាក់ថ្នាំបង្ការដែលបានចុះបញ្ជីដោយអង្គការសុខភាពពិភពលោក (WHO) ឬថ្នាំបង្ការដែលជាផ្នែកមួយនៃការធ្វើតេស្តសាកល្បងលក្ខណៈវេជ្ជសាស្ត្រ (clinical trial) នៃថ្នាំបង្ការជំងឺ COVID-19** សូមមើលតារាងនៅទំព័របន្ទាប់សម្រាប់ព័ត៌មានអំពីដូសបន្ថែម និងដូសជំរុញ។

2 **ថ្នាំបង្ការប្រភេទ Pfizer សម្រាប់កុមារដែលមានអាយុចាប់ពី 5 ទៅ 11 ឆ្នាំ**គឺមានគ្រឿងផ្សំសកម្មដូចគ្នានឹងថ្នាំបង្ការសម្រាប់មនុស្សពេញវ័យដែរ ប៉ុន្តែវាមានបរិមាណដូសតូចជាង [គឺមួយភាគបី (1/3) នៃបរិមាណដូសសម្រាប់ចាក់ដល់ក្មេងជំទង់ និងមនុស្សពេញវ័យ]។

3 **ដូសរបស់ថ្នាំបង្ការប្រភេទ Moderna មានភាពខុសគ្នា។** ថ្នាំបង្ការលំដាប់ដំបូង និងដូសបន្ថែម (ទី 3) គឺជាការចាក់ដូសដែលពេញលេញ។ ដូសជំរុញគឺជាការចាក់ដូសពាក់កណ្ដាល។

4 **ដូសបន្ថែម -** មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC) ណែនាំថាមនុស្សដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយកម្រិតមធ្យមទៅធ្ងន់ធ្ងរ ហើយដែលបានទទួលចាក់ថ្នាំបង្ការប្រភេទ mRNA (ដូចជាប្រភេទ Pfizer ឬប្រភេទ Moderna) ថ្នាំបង្ការលំដាប់ដំបូងរបស់ពួកគេ អាចធ្វើការចាក់ដូសបន្ថែម (ទី 3) បាន។ ដូសបន្ថែមគួរតែជាថ្នាំបង្ការជំងឺ COVID-19 ដែលមានប្រភេទដូចគ្នានឹងថ្នាំបង្ការលំដាប់ដំបូងរបស់ពួកគេ។ សូមពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នកអំពីតម្រូវការទទួលចាក់ដូសបន្ថែមនៃថ្នាំបង្ការជំងឺ COVID-19 និងសាកសួរអំពីពេលវេលាដ៏ល្អបំផុតដោយផ្អែកទៅលើផែនការព្យាបាលរបស់អ្នកនាពេលបច្ចុប្បន្ន។ *កំណត់សម្គាល់៖* ប្រសិនបើអ្នកមានប្រព័ន្ធភាពស៊ាំចុះខ្សោយ និងបានចាក់ថ្នាំបង្ការប្រភេទ J&J សម្រាប់ថ្នាំបង្ការលំដាប់ដំបូងរបស់អ្នក នោះអ្នកគួរតែចាក់ដូសជំរុញ។

5 **ដូសជំរុញ។** អ្នកអាចជ្រើសរើសប្រភេទថ្នាំបង្ការណាមួយដែលអ្នកចង់ចាក់ជាដូសជំរុញ។ វាអាចជាដូសជំរុញនៃថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ប្រភេទ Moderna ឬប្រភេទ J&J។ ចូរពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមានសំណួរ អំពីហានិភ័យ និងអត្ថប្រយោជន៍នៃការចាក់ដូសជំរុញ ឬអំពីប្រភេទថ្នាំបង្ការណាមួយដែលអាចចាក់ជាដូសជំរុញបាន។

6 **ប្រសិនបើអ្នកមានប្រព័ន្ធភាពស៊ាំចុះខ្សោយ** នឹងមានការចាក់ដូសនេះរយៈពេល 6 ខែបន្ទាប់ពីដូសបន្ថែម (ទី 3) របស់អ្នក។

**សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ វិធីទទួលការចាក់ថ្នាំបង្ការ ដូសសម្រាប់អ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ និង ដូសជំរុញ។**

## ដូសបន្ថែម និងដូសជំរុញសម្រាប់មនុស្សដែលបានចាក់ថ្នាំបង្ការពេញលេញ[1] ហើយដែលបានទទួលថ្នាំបង្ការដែលមិនត្រូវបានអនុញ្ញាត/អនុម័តឱ្យប្រើប្រាស់ដោយ FDA សម្រាប់លំដាប់ដំបូងរបស់ពួកគេ

<table>
<tr><th></th><th>ថ្នាំបង្ការ[2] ជំងឺ COVID-19 ដែលបានចុះបញ្ជីដោយ WHO</th><th>ថ្នាំបង្ការសកម្មដែលទទួលបានពីការធ្វើតេស្តសាកល្បងលក្ខណៈវេជ្ជសាស្ត្រនៃជំងឺ COVID-19[3]</th></tr>
<tr><td>ដូសបន្ថែម (ទី 3)[4]</td><td colspan="2">បុគ្គលណា៖ បានណែនាំយ៉ាងម៉ឺងម៉ាត់ ប្រសិនបើអ្នកមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ហើយដែលមាន ប្រព័ន្ធភាពស៊ាំខ្សោយ កម្រិតមធ្យម ឬធ្ងន់ធ្ងរ។</td></tr>
<tr><td></td><td colspan="2">ពេលណា៖ យ៉ាងហោចណាស់រយៈពេល 28 ថ្ងៃបន្ទាប់ពីការចាក់ដូសទីពីររបស់អ្នក</td></tr>
<tr><td rowspan="2">ដូសជំរុញ[4]</td><td colspan="2">បុគ្គលណា៖ បានណែនាំយ៉ាងម៉ឺងម៉ាត់ សម្រាប់មនុស្សគ្រប់គ្នាដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ។<br><br>សំខាន់ខ្លាំងណាស់ ប្រសិនបើអ្នក៖<br>• មានអាយុចាប់ពី 65 ឆ្នាំឡើងទៅ<br>• មានអាយុចាប់ពី 18 ឆ្នាំឡើងទៅ និងមានបញ្ហាសុខភាពប្រចាំកាយ (មិនបញ្ចេញមុខ) ឬប្រឈមនឹងហានិភ័យនៃការប៉ះពាល់នឹងមេរោគនៅកន្លែងការងារ ឬនៅក្នុងសហគមន៍។</td></tr>
<tr><td colspan="2">ពេលណា៖ យ៉ាងហោចណាស់រយៈពេល 6 ខែបន្ទាប់ពីដូសការចាក់ដូសទី 2 របស់អ្នក[5]។</td></tr>
</table>

1 **អ្នកត្រូវបានចាត់ទុកថាបានចាក់ថ្នាំបង្ការពេញលេញ** រយៈពេល 2 សប្ដាហ៍ បន្ទាប់ពីអ្នកបានចាក់ដូសចុងក្រោយ នៃលំដាប់ថ្នាំបង្ការនោះ។ សូមមើលគេហទំព័រ នៅពេលដែលអ្នកបានចាក់ថ្នាំបង្ការពេញលេញ សម្រាប់ព័ត៌មានលម្អិត។

2 **នេះក៏រួមបញ្ចូលផងដែរ ប្រសិនបើអ្នកបានបញ្ចប់ការចាក់លំដាប់លាយគ្នា។** លំដាប់លាយគ្នា គឺជាការរួមបញ្ចូលថ្នាំបង្ការជំងឺ COVID-19ដែលបានអនុម័ត និងបានអនុញ្ញាតឱ្យប្រើប្រាស់ដោយរដ្ឋបាលចំណីអាហារ និងឱសថ (FDA) ឬត្រូវបានចុះបញ្ជីដោយ WHO។ ថ្នាំបង្ការដែលមិនបានអនុម័ត/អនុញ្ញាតឱ្យប្រើប្រាស់ដោយ FDA តែបាន ចុះបញ្ជីដោយអង្គការសុខភាពពិភពលោក (WHO) បច្ចុប្បន្នគឺថ្នាំបង្ការប្រភេទ AstraZeneca-Oxford (ឧទាហរណ៍ ម៉ាក Covishield ឬម៉ាក Vaxzevria) ប្រភេទ Sinopharm ប្រភេទ Sinovac និងប្រភេទ Covaxin។ សូមមើលលើផ្នែក តើខ្ញុំចាក់ថ្នាំបង្ការពេញលេញនៅពេលណា? *នៅលើគេហទំព័រ នៅពេលដែលអ្នកបានចាក់ថ្នាំបង្ការពេញលេញ* ដើម្បីស្វែងយល់បន្ថែម។

3 **ប្រសិនបើអ្នកបានចូលរួមក្នុងការធ្វើតេស្តសាកល្បងលក្ខណៈវេជ្ជសាស្ត្រនៃថ្នាំបង្ការប្រភេទ AstraZeneca ឬប្រភេទ Novavax** ហើយអ្នកបានចាក់ថ្នាំបង្ការជំងឺ COVID-19 "សកម្ម" [ហើយមិនមែនជាការព្យាបាលសាកល្បង (Placebo)]។

4 **ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer គឺជាថ្នាំបង្ការតែមួយគត់ដែលត្រូវបានអនុញ្ញាត**ឱ្យប្រើប្រាស់ជាដូសបន្ថែម ឬដូសជំរុញសម្រាប់អ្នកដែលមិនបានចាក់លំដាប់ថ្នាំបង្ការដែលបានអនុញ្ញាត/អនុម័តដោយ FDA។

5 **ប្រសិនបើអ្នកមានប្រព័ន្ធភាពស៊ាំចុះខ្សោយ** នឹងមានការចាក់ដូសនេះរយៈពេល 6 ខែបន្ទាប់ពីដូសបន្ថែម (ទី 3) របស់អ្នក។

**សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ វិធីទទួលការចាក់ថ្នាំបង្ការ ដូសសម្រាប់អ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ និង ដូសជំរុញ។**